**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១១
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣
**សាលដីកា**
លេខៈ១៩២
ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម .............ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ........... ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍
៦-លោក ................. ជាចៅក្រម
៧-លោក ................ ជាចៅក្រម
៨-លោក ................. ជាចៅក្រម
៩-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ...............

**តំណាងមហាអយ្យការ**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ៤៥ (ឈ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះអគធរ (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រីអាយុ៤៤ឆ្នាំ(ស) ជាតិខ្មែរ មុខរបរមន្ត្រីរាជការរដ្ឋសភាជាតិ ទីលំនៅសព្វថ្ងៃផ្ទះលេខ៦៧៩Eo ផ្លូវលេខ១២៨ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ

ផ្ទេរសិទ្ធិឱ្យឈ្មោះសសវថអាយុ៤៣ឆ្នាំ មុខរបរប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

ចុងចម្លើយឈ្មោះហ្គោ ហ្គាណូ អាល់ប៉ៃ (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុសអាយុ៥៣ឆ្នាំ(ស) ផ្ទេរសិទ្ធិឱ្យមេធាវីឈ្មោះ..........អាស័យដ្ឋាន ផ្ទះលេខ៤៥ មហាវិថីព្រះសុរាម្រិត សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

តតិយជនអ្នកស្រីគយអាយុ៨១ឆ្នាំ ជាម្តាយបង្កើតរបស់អាល់ប៉ៃរហ្គហ្គាណូ ។

មានមេធាវីលោក ............។

<u>**កម្មវត្ថុបណ្តឹៈ**</u> <u>ប្តឹងសុំលែងលះ</u>

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១១ចុះថ្ងៃទី១៣ខែមករាឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេទលើកទី២លេខ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវីឈ្មោះ............ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៥(ឈ)ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះអគធរ ប្តឹងលែងលះប្តីឈ្មោះហ្គាហ្គាណូ អាល់ប៉ែរ ដោយសំអាងហេតុថា : ប្តីមិនគិតគូរគ្រួសារអ្វីទាំងអស់ ប្រព្រឹត្តអំពើផ្ទុយសីលធម៌ស្រវឹងមកផ្ទះវិញរករឿងប្រពន្ធកូន ជេរបញ្ចោ អាសអាភាស ជេរប្រមាថធ្ងន់ធ្ងរ ចំពោះបុព្វញាតិរបស់ខ្លួន ធ្វើទុក្ខបុកម្នេញខ្លួនស្ទើររាល់ថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៩៣(ក)ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះអគធរ ចុះថ្ងៃទី១៥-១០-១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឱ្យឈ្មោះអគធរ និងឈ្មោះហ្គាហ្គាណូ អាល់ប៉ែរ ដាច់សមគ្គសង្វាសពីគ្នាតាមការព្រមព្រៀងគ្នាចាប់ពីថ្ងៃប្រកាសាលក្រមនេះតទៅ តាមមាត្រា៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារចុះថ្ងៃទី២០-០៧-១៩៨៩ ។

៣-ឱ្យនារីអគធរ ស្ថិតនៅក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារចុះថ្ងៃទី២០-០៧-១៩៨៩ ។

៤-បែងចែកទ្រព្យសម្បត្តិភាគហ៊ុនរួមមានផ្ទះលេខ៥២Eoស្ថិតនៅផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ និងផ្ទះលេខ៣៥ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោកក្រុងភ្នំពេញ ជាពីរចំណែកស្មើគ្នា តាមតម្លៃជាក់ស្តែង គិតពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ។

៥-បង្គាប់ឱ្យឈ្មោះអគធរ បង់ប្រាក់ប្រដាប់ក្តី៧.០០០៛ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ ។ប្រាក់នេះដើមចោទ បានបង់

រួចហើយ ។ កាលបើហួសបណ្តឹងឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះហ្គាហ្គណាអាល់ប៉ែរ សងប្រាក់៧.០០០៛ នេះទៅដើមចោទវិញ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខភាគី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៩(ក)ចុះថ្ងៃទី២៨ខែកញ្ញាឆ្នាំ១៩៩៩ របស់មេធាវីឈ្មោះ ............ ការពារឱ្យដើមចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៩៣(ក) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៨ នៃសេចក្តីសម្រេចរបស់សាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០២"ក"ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ខែកញ្ញាឆ្នាំ១៩៩៩របស់លោក............ ជាមេធាវី ថណាយក្តីឱ្យឈ្មោះអគធរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៩៣"ក"ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការក្រុង ទុកជាបានការពេញទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះអគធរ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០២"ក"ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០១ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០០ របស់អ្នកស្រីអគធរ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០២(ក) ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៥០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលអ្នកស្រីអគធរ បានបង់ទុកជាមុនគឺ -ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកហ្គាហ្គាណូ អាល់បែរ សងប្រាក់ចំនួន១៩.០០០៛ នេះទៅឱ្យអ្នកស្រីអ៊ុំ គន្ធនាវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០១ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៥(ឈ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ៣២ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០១ របស់តុលាការកំពូល ។

២-សម្រេចចាត់បញ្ចូលឈ្មោះកង យន់ ភេទស្រីអាយុ៨១ឆ្នាំ មកជាទាយាទខាងភាគីចុងចម្លើយ។

៣-សម្រេចចាត់បញ្ចូលឈ្មោះភិរម្យ គន្ធលក្ខស៊ី ភេទស្រីអាយុ២២ឆ្នាំ និងឈ្មោះភិរម្យ វឌ្ឍនា ភេទប្រុសអាយុ២០ឆ្នាំ មកជាទាយាទខាងភាគីដើមចោទ ។

៤-ទទួលស្គាល់ផ្ទះលេខ៥២Eo ផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលោខ៩៥២៧ ចុះថ្ងៃទី២១-០៩-១៩៩១ របស់គណៈកម្មាធិការប្រជាជនរាជធានីភ្នំពេញ និងផ្ទះលេខ៣៥ ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ១៣៨៧ ចុះថ្ងៃទី២៥-០៣១៩៩១ របស់គណៈកម្មាធិកាប្រជាជនរាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់សពឈ្មោះអគធរ នៅពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

៥-ប្រគល់ផ្ទះលេខ៥២ Eo ផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលខ៩៥២៧ ចុះថ្ងៃទី២១-០៩-១៩៩១និងផ្ទះលេខ៣៥ ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក ក្រុងភ្នំពេញដែលវិញ្ញាបនបត្រសម្គាល់ម្ចាសល់អចលនវត្ថុលេខ១៣៨៧ ចុះថ្ងៃទី២៥-០៣-១៩៩១ ឱ្យទៅឈ្មោះភិរម្យគន្ធលក្ខស៊ី និងឈ្មោះ ភិរម្យ វឌ្ឍនាដែល ជាទាយាទរបស់សពអ្នកស្រីអគធរ កាន់កាប់ និងគ្រប់គ្រងតទៅ ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ ។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះសេង សុវត្ត ភិរម្យ គន្ធលក្ខ ស្លឹ ភិរម្យ វឌ្ឍនា និងចំពោះមុខមេធាវីតំណាងចុងចម្លើយឈ្មោះ............។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខបើកទី២លេខ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវីឈ្មោះ............ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៥(ឈ)ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ............ជាមេធាវីការពារឱ្យចុងចម្លើយ ។

បានឃើញសារណាឆ្លើយតបចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសសវថេជា តំណាងឱ្យដើមចោទ ។

បានឃើញសារណាការពារបន្ថែមចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះ............ជាមេធាវីការពារឱ្យចុងចម្លើយ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : តាងនាមតំណាងមហាអយ្យការ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ចុះ ។

បានស្តាប់ក្រឡាបញ្ជីអានសារណាការពារ របស់ឈ្មោះ............និងសារណារបស់ឈ្មោះ............ជាមេធាវីការពារអោយចុងចម្លើយ និងតតិយជនក្នុងចម្លើយ នាពេលជំនុំជំរះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសសវថេតំណាងឱ្យដើមចោទ នាពេលសវនាការថា : ការអះអាងរបស់ចុងចម្លើយ និងតតិយជន បំផ្លើសហួសពីការពិតព្រោះថា តាមទំលាប់ជន បរទេស មានលុយ គេទុកផ្ញើនៅធនាគារ មិនមាននរណាម្នាក់យកលុយឱ្យនរណាមួយទៀត ដោយមិនមានសំបុត្រនោះទេ បើចុងចម្លើយមានលុយមែន គឺចុងចម្លើយដាក់នៅឯធនាគារហើយ លោកមេធាវី អាចស្នើសុំស្រាវជ្រាវតាមលេខក្នុងនៅធនាគារប្រទេសបារាំងបានឃើញហើយ គឺគេស្រាវជ្រាវតែស្ថានភាពហិរញ្ញវត្ថុរបស់បងស្រីខ្លួន ។ ឯស្ថានភាពហិរញ្ញវត្ថុ របស់លោកហ្គាហ្គាណូ អាល់ប៊ែរ អះអាងគ្មានការពិតឡើយ ។ ម៉្យាងទៀត ផ្ទះបងស្រីខ្លួនទិញមានទំហំតូចណាស់ មិនសមនឹងលុយ២៥ម៉ឺនដុល្លាអាមេរិកដែលចុងចម្លើយបានអះអាងនោះទេ ។ ពីមុនមកមិនលេចឮរឿងនេះទេ លុះដល់ពេលលែងលះ ក៏ឮថា យកលុយ២៥ម៉ឺនដុល្លាអាមេរិកឱ្យទៅទិញផ្ទះទៅវិញ ។ កិច្ចព្រមព្រៀងជួលផ្ទះគឺតម្លៃ១២៥០ដុល្លា អាមេរិកក្នុងមួយខែ ខ្លួនមិនបានគិតទេ តែខ្លួនយល់ឃើញថា ប្រាក់ដែលតម្កល់នៅតុលាការមិនបាត់ទៅណាទេ ខ្លួនយល់ថា តាំងពីតុលាការឱ្យតម្កល់និងលុយឃើញហើយ ។ គួរពិចារណាមើលថា គាត់គ្មានផ្ទះនៅបែរឱ្យលុយទៅគេទិញផ្ទះទៅវិញ បើខ្លួនជិះកង់ មានរឿងអ្វីខ្លួនមានលុយទិញឡានCRV ឱ្យស្រីជិះនោះ ។

ខ្លួនសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ សុំផ្ទះ និងប្រាក់តម្កល់នៅតុលាការក្រុងឱ្យទាយាទកូនទាំងពីរ ព្រោះនេះជាទ្រព្យដើមរបស់អ្នកស្រីអគធរ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់តំណាងចុងចម្លើយ និងតំណាងតតិយជន ព្រមទាំងចម្លើយរបស់តំណាងដើមចេញ .

-ក្រោយបានពិភាក្សត្រឹមត្រូវតបច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវី..........ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនិងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការលើកឡើងក្នុងសារណាចុះថ្ងៃទី១០-០៦-២០០៣ របស់មេធាវី............និងសារណាបន្ថែមរបស់មេធាវី............ដោយអះអាងថា : នៅក្នុងឆ្នាំ១៩៨៨ លោកហ្គាហ្គាណូ អាល់ប៉ែរមកលេងស្រុកខ្មែរ ហើយបានប្រគល់ប្រាក់ចំនួន១២ម៉ឺនដុល្លាអាមេរិក ឱ្យទៅអ្នកស្រីអគធរ សំរាប់ទិញ ផ្ទះ និងនៅឆ្នាំ១៩៩០ លោកហ្គាហ្គាណូ អាល់បែរមកស្រុកខ្មែរម្តងទៀត ហើយក៏បានប្រគល់ប្រាក់ចំនួន១៣ម៉ឺនដុល្លាអាមេរិកទៀត ឱ្យអ្នកស្រីអគធរ សំរាប់ទិញហាងលក់គេសដ្ឋ: និងជួសជុលផ្ទះនោះពុំមានភស្តុតាង ណាមួយច្បាស់លាស់ដែលអាចឱ្យតុលាការកំពូលពិចារណាបានឡើយ ។

- យល់ឃើញថា ការដែលមេធាវីការពារអោយចុងចម្លើយសុំបែងចែកទ្រព្យសម្បត្តិ ដែលមានអចលនទ្រព្យ ផ្ទះលេខ៥២EoE$_1$ស្ថិតនៅផ្លូវលេខ១២៨ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ និងផ្ទះលេខ៣៥ ស្ថិតនៅផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់ទី២ ទណ្ឌទួលគោក ជាពីរចំណែកស្មើគ្នា តាមស្មារតីនៃមាត្រា ៣៣ និង៣៨ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា អចលនទ្រព្យទាំងពីរកន្លែងខាងលើនេះ ដែលមួយមានប័ណ្ណសំគាល់សិទ្ធិលេខ៤៥២៨ ចុះថ្ងៃទី២១-៩-៩១ និងមួយទៀតមានប័ណ្ណសំគាល់សិទ្ធិលេខ១៣៨៧ ចុះថ្ងៃទី២៥-៣-៩១ គឺមានឈ្មោះអ្នកស្រីអគធរ ជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯង ដោយគ្មានបញ្ជាក់ថា ជាកម្មសិទ្ធិរួមប្តីប្រពន្ធនោះឡើយ ។ ដូច្នេះអចលនទ្រព្យទាំងពីរ គឺពិតជាទ្រព្យដើមរបស់អ្នកស្រីអគធរ ដែលតាមច្បាប់ ត្រូវតែបានជាទ្រព្យដើមរបស់ ភាគីដើមចោទ តែម្នាក់ឯងប៉ុណ្ណោះ ។ ម៉្យាងទៀត តាមប័ណ្ណសំគាល់សិទ្ធិនៃអចលនទ្រព្យទាំងពីរនេះគឺ ធ្វើនៅឆ្នាំ១៩៩១ រីឯគូភាគីទើបតែធ្វើប័ណ្ណទទួលស្គាល់អាពាហ៍ពិពាហ៍នៅថ្ងៃទី៣០-០៨-៩៣ទេ គឺធ្វើក្រោយថ្ងៃទិញ និងថ្ងៃធ្វើប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ ។

- យល់ឃើញថា ក្នុងការសម្រេចសេចក្តីជាថ្មីឡើងវិញ សាលាឧទ្ធរណ៍ពុំបានពិចារណា និង សម្រេចអំពីប្រាក់ឈ្នួលផ្ទះលេខ៥២E0$E_1$ ដែលតុលាការកំពូលសម្រេចតាមសាលដីកាលេខ១០៩ប្រ ចុះថ្ងៃទី១៣-៦-២០០០ ត្រង់ចំណុចទី៣ ឱ្យអ្នកជួលផ្ទះយកប្រាក់ថ្លៃឈ្នួលផ្ទះលេខ៥២E0$E_1$ ទៅតម្កល់ទុកនៅតុលាការក្រុងភ្នំពេញទេ ដូច្នេះតុលាការកំពូលដែលជំនុំជំរះទាំងអង្គហេតុ និងអង្គច្បាប់ នៅពេលនេះ គប្បីលើកយកប្រាក់ដែលតម្កល់ទុកនៅតុលាការក្រុងភ្នំពេញមកសម្រេច ។

- យល់ឃើញថា ក្នុងពេលដែលលោកហ្គាហ្គាណូ អាល់ប៉ែរ និងអ្នកស្រីអគធរ នៅរស់និងស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ លោកហ្គាហ្គាណូ អាល់ប៉ែរ បានបំពេញកិច្ចជាច្រើនដើម្បីផលប្រយោជន៍ របស់គ្រួសារអ្នកស្រីអគធរ ដូចជាធានាយកអ្នកស្រីអគធរ ព្រមទាំងកូនអ្នកស្រីអ៊ុគន្ធនារីទាំងពីរ នាក់ទៅរស់នៅប្រទេសបារាំងហើយ បំពេញកិច្ចធានារហូតដល់ម្តាយនិងកូននេះបានចូលជាសញ្ជាតិបារាំង ទៀត ។ ប៉ុន្តែពេលនេះអ្នកស្រីអគធរ បានទទួលមរណភាពទៅហើយ នៅសល់ទាយាទជាកូន០២ នាក់ដែលត្រូវទទួលមរតកជាផ្ទះពីរកន្លែង និងថ្លៃឈ្នួលផ្ទះ ប៉ុន្តែលោកហ្គាហ្គាណូ អាល់ប៉ែរ ក្រោយពេល ទទួលមរណភាពទៅនៅសល់ទាយាទជាម្តាយដែលចាស់ជរាគ្មានទ្រព្យសម្បត្តិអ្វីដើម្បីរស់នៅបន្តភាពចាស់ ជរារបស់ខ្លួនទេ ។ ដូច្នេះ ផ្អែកតាមគោលការណ៍ប្រព្រៃណីល្អ និងសមធម៌ ដែលមានចែងក្នុងមាត្រា៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រ៣៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារតុលាការកំពូល គប្បីសម្រេចដកយកប្រាក់ថ្លៃឈ្នួលផ្ទះដែលតម្កល់ទុកនៅតុលាការក្រុងភ្នំពេញ ខ្លះដែលបានជួលក្នុងពេលចំណងអាពាហ៍ពិពាហ៍មិនទាន់ត្រូវបានរំលាយ ឧបត្ថម្ភដល់តតិយជនជាទាយាទ ឈ្មោះកង យន់ ដើម្បីអាចបន្តជីវិតរស់នៅក្នុងភាពចាស់ជរា ។

- យល់ឃើញថា កម្មវត្ថុនៃការទាមទាររបស់គូភាគី គឺផ្ទះលេខ៣៥ ផ្ទះលេខ៥២ E0 $E_1$និងE2ប៉ុន្តែ សាលាឧទ្ធរណ៍បានសម្រេចតែផ្ទះលេខ៣៥ និងលេខ៥២$E_1$ ប៉ុណ្ណោះ នៅពុំទាន់បានសម្រេចអំពីផ្ទះលេខ៥២$E_1$ និង $E_2$ ទេ ។ ប៉ុន្តែដោយតំណាងដើមចោទពុំបានប្តឹងសាទុក្ខពីសាលដីកាសាលាឧទ្ធរណ៍ជាលើកទី២ទៀតនោះ តុលាការកំពូល ពុំមានសមត្ថកិច្ចលើកយកផ្ទះលេខ៥២៩ និង៥២ $E_2$ មកសម្រេចបានទេ ។

- យល់ឃើញថា តំណាងចុងចម្លើយ និងតំណាងតតិយជន បានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ហើយក៏បានទទួលដីកាកោះឱ្យមកចូលរួមនាសវនាការនេះដែរ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេដោយតំណាងតតិយជនសុំពន្យាពេលសវនាការដោយពុំមានភស្តុតាងច្បាស់លាស់ ដូច្នេះ តុលាការកំពូលជំនុំជំរះក៏បាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៥(ឈ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយដោយគ្រាន់តែសម្រេចមិនអស់ នូវកម្មវត្ថុនៃរឿងទំនាស់ ដែលគប្បីតុលាការកំពូលសម្រេចបន្ថែមឱ្យបានគ្រប់គ្រាន់ ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងដើមចោទកំបាំងមុខតំណាងចុងចម្លើយ និងតំណាងតតិជន ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១៧៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ របស់មេធាវី............ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៥ (ឈ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលដោយគ្រាន់តែបន្ថែមចំណុចៈ

ប្រាក់ថ្លៃឈ្នួលផ្ទះ ដែលបានតម្កល់ទុកនៅតុលាការក្រុងភ្នំពេញ ត្រូវផ្តល់ជូនអ្នកស្រីកង យន់ ជាទាយាទរបស់លោក ហ្គាហ្គាណូ អាល់ប៊ែរ ចំនួន១៥.០០០ដុល្លាអាមេរិក(មួយម៉ឺនប្រាំពាន់គត់) ប្រាក់សល់ពីនេះត្រូវប្រគល់ឱ្យកូនទាំងពីរ ដែលជាទាយាទរបស់សពអ្នកស្រីអគធរ ទាំងអស់ ។ ក្រោយ ពេលសាលដីកានេះចូលជាស្ថាពរទាយាទនៃសពអ្នកស្រីអគធរ មានសិទ្ធិបើកប្រាក់ថ្លៃឈ្នួលផ្ទះដោយ ផ្ទាល់ពីអ្នកជួល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលតំណាងដើមចោទបានបង់ជួសនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយបង្គាប់ឲ្យតំណាងចុងចម្លើយសងប្រាក់១៩.០០០៛ នេះទៅតំណាងដើមចោទវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៨ខែកញ្ញាឆ្នាំ២០០៣.